**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 01-Feb-2012, 15:41
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យប្រភេទចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបដិសេធសំណើរបស់គាត់ស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់មន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួនរក្សាការប្រាស្រ័យទាក់ទងដោយចំហរ និងដោយតម្លាភាពជាមួយភាគីទាំងអស់**

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះតុលាការកំពូល:
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម Motoo NOGUCHI
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម A. KLONOWIECKA-MILART
ចៅក្រម មុំង មុន្នីចរិយា
ចៅក្រម C. N. JAYASINGHE

**ចម្លងជូន:**
ជនជាប់ចោទ:
នួន ជា
អៀង សារី
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe

ចៅក្រម យ៉ា ណារិន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Elisabeth SIMONNEAU FORT

លោក អាង ឧត្តម
លោក Michael G.KARNAVAS
លោក គង់ សំអុន
លោក Arthur VERCKEN
លោក Jacques VERGÈS

## I. សេចក្តីផ្តើម

១- នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០១២ មេធាវីការពារក្តី អៀង សារី ("មេធាវីការពារក្តី") បានដាក់បណ្តឹងសាទុក្ខមួយ[1] ជូនអង្គជំនុំជម្រះតុលាការកំពូល("អង្គជំនុំជម្រះ") ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១១ ("សេចក្តីសម្រេចដែលរងការជំទាស់")[2]។ សេចក្តីសម្រេចដែលរងការជំទាស់នេះ បានច្រានចោលសំណើមួយដែលបានដាក់ដោយមេធាវីការពារក្តី ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង បង្គាប់មន្ត្រីច្បាប់ជាន់ខ្ពស់ឱ្យចម្លងជូនគ្រប់ភាគីទាំងអស់នូវគ្រប់ការប្រាស្រ័យទាក់ទងទាំងអស់ ពាក់ព័ន្ធនឹងបញ្ហានៃការគ្រប់គ្រងសវនាការជំនុំជម្រះ ("សំណើ")[3]។ នៅក្នុងបណ្តឹងសាទុក្ខនេះ មេធាវីការពារក្តីស្នើអង្គជំនុំជម្រះ : បើកសវនាការផ្ទាល់មាត់ជាសាធារណៈមួយស្តីពីបញ្ហាដែលបានលើកនៅក្នុងបណ្តឹងសាទុក្ខនេះ; ទុកជាមោឃៈនូវសេចក្តីសម្រេចដែលរងការជំទាស់ និងបង្គាប់ឱ្យអង្គជំនុំជម្រះសាលាដំបូង "បញ្ឈប់ និងធ្វើឱ្យលែងមានទៀតនូវការបង្គាប់មន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួន ចូលរួមក្នុងការប្រាស្រ័យទាក់ទងដែលមាន*តែម្ខាង*"។

២- មេធាវីការពារក្តីអះអាងដោយពឹងផ្អែកលើវិធាន១០៤(១), ១០៤(៤)(ឃ) និង២១ ជាទឡ្ហីករណ៍សម្រាប់ភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខនេះ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា បណ្តឹងសាទុក្ខនេះជាក់ស្តែងណាស់ថា មិនអាចទទួលយកបានក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះទេ។ ទន្ទឹមនេះ សហព្រះរាជអាជ្ញាសូមស្នើដល់អង្គជំនុំជម្រះប្រកាសថា បណ្តឹងសាទុក្ខនេះមិនអាចទទួលយកបានឡើយ ហើយច្រានចោលសំណើដែលស្នើសុំឱ្យមានសវនាការផ្ទាល់មាត់ជាសាធារណៈ។ លើសពីនេះ តាមទម្លាប់នៃការអនុវត្តជាបន្តបន្ទាប់របស់មេធាវីការពារក្តី ក្នុងការដាក់បណ្តឹងសាទុក្ខដែលមិនអាចទទួលយកបានយ៉ាងជាក់ស្តែងដូច្នេះ សហព្រះរាជអាជ្ញាសូមស្នើឱ្យអង្គជំនុំជម្រះបញ្ជូន

---

[1] **E154/1/1/1** បណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបដិសេធសំណើរបស់គាត់ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់មន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួនរក្សាការប្រាស្រ័យទាក់ទងដោយចំហរ និងដោយតម្លាភាពជាមួយគូភាគីទាំងអស់, ១២ មករា ២០១២ (បានជូនដំណឹងជាភាសាអង់គ្លេស នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១២ និងជាភាសាខ្មែរ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១២) ("បណ្តឹងសាទុក្ខ")។

[2] **E154/1** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា *សំណើរបស់ អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់រក្សាការប្រាស្រ័យទាក់ទងការងារដោយចំហរ និងដោយតម្លាភាពជាមួយភាគីទាំងអស់ ពាក់ព័ន្ធនឹងបញ្ហារៀបចំសវនាការ,* ២០ ធ្នូ ២០១១ ("សេចក្តីសម្រេចដែលរងការជំទាស់")។

[3] **E154** *សំណើរបស់ អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់រក្សាការប្រាស្រ័យទាក់ទងការងារដោយចំហរ និងដោយតម្លាភាពជាមួយភាគីទាំងអស់ ពាក់ព័ន្ធនឹងបញ្ហារៀបចំសវនាការ,* ១៤ ធ្នូ ២០១១ ("សំណើ")។

បញ្ហានេះទៅផ្នែកអង្គភាពគាំពារការពារក្តី សម្រាប់ការវាយតម្លៃថា តើការងារដែលបានបំពេញនៅក្នុងបណ្តឹងសាទុក្ខ គឺជាការចាំបាច់ និងសមហេតុផលដែរ ឬអត់។

## I. បណ្តឹងសាទុក្ខមិនអាចទទួលយកបាន

*គេគ្មានមូលដ្ឋានច្បាប់សម្រាប់ឲ្យទទួលយកបណ្តឹងសាទុក្ខ នៅក្រោមវិធាន១០៤(១) ទេ*

៣- មេធាវីការពារក្តីអះអាងថា បណ្តឹងសាទុក្ខគឺអាចឲ្យទទួលយកបាន នៅក្រោមវិធាន១០៤(១) ដោយហេតុថា សេចក្តីសម្រេចដែលរងការជំទាស់ មានការពាក់ព័ន្ធនឹងការភ័ន្តច្រឡំផ្នែកអង្គច្បាប់ ការច្រឡំលើអង្គហេតុ និងការរំលោភបំពានឆន្ទានុសិទ្ធិ[4]។

៤- អំណះអំណាងនេះ គឺជាការយល់ច្រឡំដោយចេតនា ក្នុងការអានលើវិធាន១០៤ និងដាក់បញ្ចូលនូវបទប្បញ្ញត្តិស្តីពីយុត្តាធិការទូទៅរបស់អង្គជំនុំជម្រះដែលមាននៅក្នុងវិធាន១០៤(១) ជាមួយនឹងបញ្ជីនៃកិច្ចការផ្សេងៗជាកម្មវត្ថុនៃបណ្តឹងសាទុក្ខភ្លាមៗដូចបានរៀបរាប់នៅក្នុងវិធាន១០៤(៤)។ វិធាន១០៤(១) គឺជាបទប្បញ្ញត្តិទូទៅមួយដែលកំណត់អំពីទឡ្ហីករណ៍ផ្សេងៗ ដែលអង្គជំនុំជម្រះត្រូវយកទៅពិចារណាសម្រេចលើគ្រប់បណ្តឹងសាទុក្ខ*ទាំងអស់*។ ម្យ៉ាងវិញទៀត វិធាន១០៤(៤) គឺជាបទប្បញ្ញត្តិជាក់លាក់មួយដែលកំណត់ជាក់លាក់ អំពីប្រភេទនៃសេចក្តីសម្រេចចំនួនបួនដែលជាកម្មវត្ថុនៃបណ្តឹងសាទុក្ខ*ភ្លាមៗ*។ វិធាន១០៤(៤) ចែងបន្ថែមទៀតថា "សេចក្តីសម្រេចផ្សេងទៀត អាចប្តឹងសាទុក្ខបានតែក្នុងករណីដែលបានធ្វើឡើងស្របពេលជាមួយបណ្តឹងសាទុក្ខពីសាលក្រមលើអង្គសេចក្តី"[5]។

៥- នៅពេលបទប្បញ្ញត្តិទាំងនេះត្រូវបានគេអានរួមគ្នា និងដោយសារអត្ថន័យធម្មតារបស់វា គឺច្បាស់គ្មានអ្វីជាមន្ទិលទាល់តែសោះថា វិធាន១០៤(១) មិនបានចែងកំណត់អំពីមូលដ្ឋានមិនចំណុះណាមួយសម្រាប់ការប្តឹងសាទុក្ខភ្លាមៗណាមួយប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងណាមួយឡើយ។ ផ្ទុយទៅវិញ មានតែបញ្ហាទាំងឡាយដែលមានចែងកំណត់ក្នុងវិធាន១០៤(៤)(ក)-(ឃ) ប៉ុណ្ណោះ អាចជាកម្មវត្ថុនៃបណ្តឹងសាទុក្ខភ្លាមៗ។ ការបកស្រាយដូចនេះគឺជាស្របគ្នាមួយជាមួយនឹងសេចក្តីសម្រេចមុនៗរបស់អង្គជំនុំជម្រះ រួមទាំងសេចក្តីសម្រេចមួយចុះកាលបរិច្ឆេទមួយសប្តាហ៍នៅ

---

[4] **E154/1/1/1** បណ្តឹងសាទុក្ខ, កំណត់សំគាល់*ខាងដើម*លេខ១ ត្រង់កថាខ័ណ្ឌទី៥-៧។

[5] វិធាន១០៤(៤) (សង្កត់ន័យពាក្យក្នុងរង់ក្រចក)។

មុនការដាក់បណ្តឹងសាទុក្ខនេះដែលនៅក្នុងសេចក្តីសម្រេចនោះ អង្គជំនុំជម្រះបានរកឃើញថា យុត្តាធិការរបស់ខ្លួននៅលើបណ្តឹងសាទុក្ខកម្រិតត្រឹមតែកិច្ចការទាំងឡាយ ដូចបានកំណត់ក្នុងវិធាន១០៤(៤) ប៉ុណ្ណោះ[6]។

*មិនមានមូលដ្ឋានច្បាប់សម្រាប់ភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខ*
*តាមវិធាន១០៤(៤)(ឃ)នៃវិធានផ្ទៃក្នុងនោះទេ*

៦- លើសពីនេះទៅទៀត មេធាវីការពារក្តីបានអះអាងថា បណ្តឹងសាទុក្ខអាចទទួលយកបាន ពីព្រោះ "បណ្តឹងសាទុក្ខនេះពាក់ព័ន្ធនឹងការជ្រៀតជ្រែកចូលនៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការដែលនៅក្រោមវិធាន៣៥(៦)នៃវិធានផ្ទៃក្នុង"[7] ហើយដែលហេតុនេះត្រូវដាក់ឲ្យស្ថិតនៅក្នុងការប្តឹងសាទុក្ខភ្លាមៗតាមវិធាន ១០៤(៤)នៃវិធានផ្ទៃក្នុង ដោយយោងទៅលើ "សេចក្តីសម្រេចមួយស្តីពីការជ្រៀតជ្រែកចូលនៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការដែលនៅក្រោមវិធាន៣៥(៦)នៃវិធានផ្ទៃក្នុង"។

៧- មិនមានមូលដ្ឋានច្បាប់ណាដែលគួរឲ្យជឿបាន ដើម្បីធ្វើការបកស្រាយលើសេចក្តីសម្រេចដែលកំពុងមានបញ្ហា ថាជា "*សេចក្តីសម្រេច*" ស្តីពីការជ្រៀតជ្រែកចូលនៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការដែលនៅក្រោមវិធាន៣៥(៦)នៃវិធានផ្ទៃក្នុងនេះឡើយ"។ សេចក្តីសម្រេចដែលកំពុងមានបញ្ហា មិនបានយោង ឬទាក់ទងគ្នាបែបណាមួយទៅនឹងការជ្រៀតជ្រែកចូលនៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការ ដូចដែលមាននៅក្នុងខ្លឹមសារនៃវិធាន៣៥ នៃវិធានផ្ទៃក្នុងទេ"។ នេះគឺជាការដែលអាចឲ្យយល់បានថា ដោយសារនៅក្នុងសំណើនេះផ្ទាល់មិនបានអំពាវនាវសុំឲ្យមានការស៊ើបសួរណាមួយអនុលោមតាមវិធាន៣៥ ឬម៉្យាងទៀតក៏មិនបានចោទប្រកាន់ថា ការអនុវត្តដែលកំពុងជាប់បន្ទុកនោះ គឺវាស្មើនឹងការជ្រៀតជ្រែកចូលនៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការដែរ"។ ឥឡូវនេះ ប្រការដែលថាមេធាវីការពារក្តីបានខំប្រឹងទាមទារឲ្យធ្វើការបកស្រាយទៅលើការចេញ

---

[6] **E130/4/3** *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យជនជាប់ចោទមានវត្តមានក្នុងសាលសវនាការ,* ១៣ មករា ២០១២, ទំព័រទី២។ សូមអានផងដែរ ឯកសារលេខ **E169/1/2** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខ ដែលបានដាក់ដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម២ និងក្រុម៣ ប្រឆាំងនឹងសេចក្តីសម្រេចធ្វើឡើងដោយផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩, ២៤ ធ្នូ ២០០៩ ត្រង់កថាខ័ណ្ឌទី១០-១២។

[7] ឯកសារលេខ **E130/4/1** បណ្តឹងសាទុក្ខ , កំណត់សំគាល់លេខ១ *ខាងលើ* ត្រង់កថាខណ្ឌទី៨-១០។

សេចក្ដីសម្រេចដែលកំពុងមានបញ្ហានោះតែម្ដងថា ជាការជ្រៀតជ្រែកចូលនៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការ គឺវាមិនទាន់គ្រប់គ្រាន់ដើម្បីនឹងដាក់បញ្ចូលសេចក្ដីសម្រេចដែលកំពុងមានបញ្ហានៅក្រោមវិធាន៣៥(៦)នៃវិធានផ្ទៃក្នុងនោះឡើយ”។ ការបកស្រាយបែបនេះមុខជានឹងនាំឱ្យទទួលបានលទ្ធផលដែលមិនសមហេតុសមផលឡើយ ដែលតាមរយៈនេះ ភាគីណាមួយក៏អាចនឹងដាក់បណ្ដឹងសាទុក្ខភ្លាមៗបាន ប្រឆាំងនឹងសេចក្ដីសម្រេច*ណាមួយ* របស់អង្គជំនុំជម្រះសាលាដំបូងដែរ ដោយគ្រាន់តែចោទប្រកាន់ថា សេចក្ដីសម្រេចនោះបានជ្រៀតជ្រែកចូលនៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការតែប៉ុណ្ណោះ។

៨- ជាបញ្ហាខាងខ្លឹមសារ ការដែលចោទប្រកាន់ថាអង្គជំនុំជម្រះសាលាដំបូង តាមការចេញសេចក្ដីសម្រេចដែលកំពុងមានបញ្ហានេះ“គឺបានជ្រៀតជ្រែកចូលនៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការ ដោយបានដឹង និងដោយចេតនា” ដែលការចោទប្រកាន់នោះមិនមានមូលដ្ឋានត្រឹមត្រូវទាំងស្រុង និងជាការវាយប្រហារទៅលើសុចរិតភាពរបស់អង្គជំនុំជម្រះសាលាដំបូង។ ជាងនេះទៅទៀត ការចោទប្រកាន់នេះបានបំភ្លេចចំពោះស្មារតី និងអត្ថន័យយ៉ាងច្បាស់លាស់នៃសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ ដែលក្នុងនោះបានសម្រេចថា៖ “ទាំងកំហុសខាងអង្គហេតុណាមួយក្ដី ឬទាំងការរំលោភលើឆន្ទានុសិទ្ធិពីសំណាក់អង្គជំនុំជម្រះសាលាដំបូងក្ដី គឺសុទ្ធតែមិនអាចបង្កើតបានដោយផ្ទាល់ទៅជាការជ្រៀតជ្រែកចូលនៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការដោយបានដឹង និងដោយចេតនា តាមអត្ថន័យដូចដែលបានចែងនៅក្នុងវិធាន៣៥នៃវិធានផ្ទៃក្នុង”[8]នោះឡើយ។ ការព្យាយាមធ្វើឃើញខុសប្លែកពីគ្នានូវសេចក្ដីសម្រេចដែលធ្វើឱ្យមានបញ្ហានេះ នៅក្នុងបណ្ដឹងសាទុក្ខបានចោទប្រកាន់ថា នៅក្នុងករណីបច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូង “មិនគ្រាន់តែមានកំហុសខាងអង្គហេតុ និងអង្គច្បាប់ ឬរំលោភទៅលើឆន្ទានុសិទ្ធិរបស់ខ្លួនប៉ុណ្ណោះទេ” ប៉ុន្តែថែមទាំងបានជាប់ពាក់ព័ន្ធនៅ “ក្នុងការប្រព្រឹត្តដែលគ្មានមនសិកា”ទៀតផង ដែលមានស្ថានទម្ងន់ស្មើនឹងឧទាហរណ៍នានាដូចដែលបានរៀបរាប់ជាបញ្ជីនៅក្នុងវិធាន៣៥ និងបានបង្ហាញឱ្យឃើញពី “អំពើខុសឆ្គងដែលលក្ខខណ្ឌតម្រូវឱ្យមាន”ក្នុងការរំលោភទៅលើវិធាន៣៥នៃវិធានផ្ទៃក្នុង[9]។ ក៏ប៉ុន្តែ លើសពីការចង្អុលបង្ហាញពីការចេញដីកាសម្រេចដែលកំពុងមានបញ្ហា និងការរំឭកឡើងវិញអំពីផលប្រយោជន៍នានា

[8] ឯកសារលេខ **E130/4/3** សាលដីកាសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងដែលតម្រូវឱ្យគាត់មានវត្តមានផ្ទាល់នៅក្នុងតុលាការ,ចុះថ្ងៃទី១៣ មករា ២០១២ ទំព័រ២។

[9] ឯកសារលេខ **E130/4/1** បណ្ដឹងសាទុក្ខ , កំណត់សំគាល់លេខ១ *ខាងលើ* ត្រង់កថាខណ្ឌទី៩-១០។

ដែលត្រូវបានធ្វើឲ្យខូចខាតតាមរយៈសេចក្តីសម្រេចនេះ នៅក្នុងបណ្តឹងសាទុក្ខមិនបានផ្តល់នូវភស្តុតាង មួយចំរៀកណាមួយសូម្បីតែបន្តិចក៏គ្មានដែរ ដើម្បីចង្អុលបង្ហាញភ័ស្តុតាងអំពីការចោទប្រកាន់ដ៏ធ្ងន់ធ្ងរនេះ។

*មិនមានមូលដ្ឋានច្បាប់ណាសម្រាប់ភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខតាមវិធាន២១នោះទេ*

៩- ជាចុងក្រោយ មេធាវីការពារក្តីពោលអះអាងថា បណ្តឹងសាទុក្ខគឺអាចទទួលយកបានដោយផ្អែកលើមូលដ្ឋាននៃវិធាន២១នៃវិធានផ្ទៃក្នុងតែមួយគត់ប៉ុណ្ណោះ ដោយសារតែវិធាននេះតម្រូវឲ្យអង្គជំនុំជម្រះ "ជានិច្ចកាលត្រូវតែរក្សាការពារផលប្រយោជន៍នានារបស់លោក អៀង សារី"[10]។ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា វិធាន២១គឺជាបញ្ញត្តិទូទៅមួយដែលសំរាប់យកមកអនុវត្តជាសំខាន់បំផុតធ្វើជាវិធានមួយសំរាប់ធ្វើការបកស្រាយ។ វិធាននេះមិនអាចលប់លើខ្លឹមសារដែលច្បាស់លាស់ និងដែលគ្មានភាពស្រពិចស្រពិលនៃវិធាន១០៤(៤) នៃវិធានផ្ទៃក្នុងនោះបានឡើយ ដែលក្នុងនោះបានចែងថា មានសេចក្តីសម្រេចតែបួនប្រភេទប៉ុណ្ណោះដែលអាចឲ្យធ្វើបណ្តឹងសាទុក្ខភ្លាមៗបាន និងរក្សាសិទ្ធិប្តឹងសាទុក្ខប្រឆាំងនឹងរាល់សេចក្តីសម្រេចទាំងអស់ដទៃទៀត នៅក្នុងដំណាក់កាលក្រោយៗទៀតនៃកិច្ចដំណើរការសវនាការ។ ដូចដែលបានបញ្ជាក់ពីខាងលើ អង្គជំនុំជម្រះនេះបានសម្រេចកាលពីមុនរួចមកហើយថា យុត្តាធិការរបស់ខ្លួនលើបណ្តឹងសាទុក្ខភ្លាមៗ ត្រូវបានកម្រិតកំណត់ត្រឹមតែលើបញ្ហានានាដូចដែលមានចែងនៅក្នុងវិធាន១០៤(៤)នៃវិធានផ្ទៃក្នុង[11]។

១០- មេធាវីការពារក្តីបានស្វែងរកការពឹងផ្អែកលើសេចក្តីសម្រេចពីររបស់អង្គបុរេជំនុំជម្រះ ដើម្បីគាំទ្រអំណះអំណាងរបស់ខ្លួនថា វិធាន២១ បានចែងពីមូលដ្ឋានឯករាជនៃបណ្តឹងសាទុក្ខ[12]។ យ៉ាងណាក៏ដោយ សេចក្តីសម្រេចទាំងនេះទាក់ទងទៅនឹងការបកស្រាយវិធាន៧៤.៣ ជាបញ្ញត្តិមានពាក្យ

[10] ឯកសារលេខ **E130/4/1** បណ្តឹងសាទុក្ខ , កំណត់សំគាល់លេខ១ *ខាងលើ* ត្រង់កថាខណ្ឌទី១១។

[11] ឯកសារលេខ **E130/4/3** សាលដីកាសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងដែលតម្រូវឲ្យគាត់មានវត្តមានដោយផ្ទាល់នៅក្នុងតុលាការ,ចុះថ្ងៃទី១៣ មករា ២០១២ ទំព័រ២ ។ សូមអានផងដែរនូវឯកសារលេខ **E169/1/2** សាលដីកាសម្រេចលើបណ្តឹងសាទុក្ខដែលបានដាក់ដោយសហមេធាវីការពារក្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម២ និងក្រុម៣) ប្រឆាំងនឹងសេចក្តីសម្រេចដោយផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី២៧ សីហា ២០០៩, ថ្ងៃទី២៤ ធ្នូ ២០០៩ ត្រង់កថាខណ្ឌពីទី១០-១២។

[12] **E130/4/1** បណ្តឹងសាទុក្ខ, កំណត់សម្គាល់*ខាងលើ* លេខ១ ត្រង់កថាខ័ណ្ឌទី ១១ និង សេចក្តីសម្រេចដែលបានចែងនៅក្នុងនោះ។

ពេចន៍ខុសគ្នា ដែលស្តីពីការគ្រប់គ្រងលទ្ធភាពបណ្តឹងសាទុក្ខធ្វើឡើងដោយជនជាប់ចោទនៅ ដំណាក់កាលសវនាការមុនអង្គសេចក្តី។ វិធាន៧៤.៣ បានរៀបរាប់អំពីប្រភេទនៃដីកា ឬសេចក្តីសម្រេចនានារបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលជាប្រធានបទនៃការប្តឹងសាទុក្ខ។ វាមិនដូចជាវិធាន១០៤.៤ នោះទេ គឺវាមិនមែនចែងអំពីយន្តការប្តឹងសាទុក្ខណាមួយ ដែលជំទាស់ទៅនឹងដីកា ឬសេចក្តីសម្រេចនានា ដែលនឹងត្រូវប្តឹងសាទុក្ខនៅដំណាក់កាលក្រោយៗ មកទៀតនៃកិច្ចដំណើរការនីតិវិធីនោះឡើយ។ អង្គបុរេជំនុំជម្រះបានពឹងផ្អែកលើវិធាន២១ ក្នុងការធ្វើការបកស្រាយយ៉ាងទូលំទូលាយអំពីសិទ្ធិប្តឹងសាទុក្ខនៅដំណាក់កាលសវនាការមុនអង្គសេចក្តី ដោយហេតុថាបើពុំដូច្នោះទេ ជនជាប់ចោទនឹងមិនមានឱកាសប្តឹងសាទុក្ខឡើយ។ នៅក្នុងករណី រឿងបច្ចុប្បន្ននេះ គេពុំចាំបាច់ធ្វើការដោះស្រាយតាមវិធាន២១ ដោយសារសិទ្ធិរបស់ជនជាប់ចោទ ស្តីពីសិទ្ធិក្នុងការទទួលបាននូវការកាត់ក្តីដោយត្រឹមត្រូវ ត្រូវបានរក្សាការពារយ៉ាងគ្រប់គ្រាន់ដោយបទប្បញ្ញត្តិស្តីពីសិទ្ធិក្នុងការប្តឹងសាទុក្ខលើសេចក្តីសម្រេចដែលកំពុងប្តឹងទាស់ នៅដំណាក់កាលចុងក្រោយនៃកិច្ចដំណើរការនីតិវិធី។

## III. មេធាវីការពារក្តីធ្លាប់បានអនុវត្តដាក់ឯកសារស្តីពីបណ្តឹងសាទុក្ខភ្លាមៗ ដែលជាក់ស្តែងមិនអាចឱ្យទទួលយកបាន

១១- ដូចដែលសហព្រះរាជអាជ្ញាបានធ្វើការកត់សម្គាល់ពីមុនរួចមកហើយថា មេធាវីការពារក្តីធ្លាប់បានអនុវត្តដាក់ឯកសារស្តីពីបណ្តឹងសាទុក្ខភ្លាមៗដែលជាក់ស្តែងមិនអាចឱ្យទទួលយកបាន[13]។ ជាការពិតហើយដែលបណ្តឹងសាទុក្ខបច្ចុប្បន្នមួយនេះត្រូវបានដាក់តិចជាងមួយសប្តាហ៍ ក្រោយពេលដែលអង្គជំនុំជម្រះបានចេញសេចក្តីសម្រេចមួយ ដោយហេតុមិនអាចទទួលយកបាន ច្រានចោលនូវបណ្តឹងសាទុក្ខពីមុនមួយដែលបានដាក់ដោយមេធាវីការពារក្តី ដែលសំអាងនៅលើអំណះអំណាងតាមផ្លូវច្បាប់ដូចគ្នាដែល ពាក់ព័ន្ធទៅនឹងវិធាន១០៤ និង៣៥.៨[14]។ ការអនុវត្តបំពានលើនីតិវិធីរបស់ អវតក ជាបន្តបន្ទាប់នេះ មានបន្ទុកធ្ងន់ទៅលើធនធាន និងពេលវេលាដែលមិនគ្រប់គ្រាន់

[13] សូមអាន **E130/4/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលា ដំបូង ដែលតម្រូវឱ្យជនជាប់ចោទត្រូវមានវត្តមានដើម្បីស្តាប់ការចោទប្រកាន់ និងសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់, ថ្ងៃទី១២ មករា ២០១២ ត្រង់កថាខណ្ឌទី ១១។

[14] **E130/4/3** *សាលដីកាលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យជនជាប់ចោទមានវត្តមានក្នុងសាលសវនាការ,* ថ្ងៃទី១៣ មករា ២០១២។

របស់អង្គជំនុំជម្រះ ក៏ដូចជារបស់ភាគីនានាដែរ ហើយវាបានបង្ហាញពីការមិនយកចិត្តទុកដាក់ទៅលើសេចក្តីសម្រេចនានារបស់អង្គជំនុំជម្រះ ស្តីពីភាពអាចទទួលបាននូវបណ្តឹងសាទុក្ខភ្លាមៗទាំងនេះ។ នៅលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា អង្គជំនុំជម្រះត្រូវតែបញ្ជូនកិច្ចការដែលបានបំពេញដោយសហមេធាវីការពារក្តីរបស់ អៀង សារី អំពីបណ្តឹងសាទុក្ខបច្ចុប្បន្នមួយនេះ ទៅឲ្យអង្គភាពគាំពារការការពារក្តី ដើម្បីធ្វើការវាយតម្លៃមួយថា តើកិច្ចការមួយនេះមានទាំងភាពចាំបាច់ និងទាំងសមហេតុផលដែរ ឬទេ[15]។

## IV. ដំណោះស្រាយដែលស្នើសុំ

១២- ចំពោះមូលហេតុនានាដែលមាននៅខាងដើមនេះ សហព្រះរាជអាជ្ញា សូមស្នើដល់ អង្គជំនុំជម្រះដោយគោរពថា៖

(១) ចាត់ទុកថា បណ្តឹងសាទុក្ខនេះគឺមិនអាចទទួលយកបានទាំងស្រុង,

(២) បដិសេធសំណើរបស់សហមេធាវីការពារក្តី ដែលស្នើសុំឲ្យមានសវនាការមួយជាសាធារណៈ និងដោយផ្ទាល់មាត់, និង

(៣) បញ្ជូនបញ្ហានេះទៅឲ្យអង្គភាពគាំពារការការពារក្តី ដើម្បីធ្វើការវាយតម្លៃមួយថា តើកិច្ចការដែលបានបំពេញអំពីបណ្តឹងសាទុក្ខនេះ មានទាំងភាពចាំបាច់ និងទាំងសមហេតុផល ដែរឬទេ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
| --- | --- | --- | --- |
| ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១២ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Andrew CAYLEY** សហព្រះរាជអាជ្ញា | | [signature] |

[15] អនុលោមតាមវិធាន១១.២.ជ និងមាត្រា ១០ នៃគោលការណ៍ណែនាំស្តីពីបែបបទជំនួយខាងផ្លូវច្បាប់សម្រាប់អវតក។